ព្រឹទ្ធសភា

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែកញ្ញា ឆ្នាំ២០១៩

*នៅក្នុងខែកញ្ញា ឆ្នាំ២០១៩នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ៖*

## ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១-សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន :

*-ទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីចំនួន០១លើក*

*-ទទួលសារតាំងពីឯកឧត្តម* Mikami MASAHIRO *ឯកអគ្គរាជទូតតែងតាំងថ្មីនៃព្រះរាជាណាចក្រជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា*

*-អនុញ្ញាតជូនឯកឧត្តមបណ្ឌិត* ***មហាធា មហាម៉ាត់*** *នាយករដ្ឋមន្ត្រីម៉ាឡេស៊ី និងគណៈប្រតិភូជាន់ខ្ពស់ចូលជួបសវនាការ និងសម្តែងការគួរសម*

*-អនុញ្ញាតជូនឯកឧត្តម* ***ថងលុន ស៊ីសុលីត*** *នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងគណៈប្រតិភូចូលជួបសវនាការ និងសម្តែងការគួរសម*

*-អញ្ជើញជួបសំណេះសំណាល និងសាកសួរសុខទុក្ខបងប្អូនប្រជាពលរដ្ឋ នៅកំពង់ផែក្រុងក្រចេះ ខេត្តក្រចេះ និងប្រជាពលរដ្ឋដែលកំពុងទទួលរងផលប៉ះពាល់ និងរងគ្រោះដោយសារទឹកជំនន់ នៅភូមិកណ្តាលកោះ ស្រុកកោះសូទិន ខេត្តកំពង់ចាម*

*-អញ្ជើញចូលរួមក្នុងពិធីកាន់បិណ្ឌវេនទី៦ និងប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធសម្តេចអគ្គមហាធម្មពោធិសាល* ***ជា ស៊ីម*** *និងលោកជំទាវ* ***ញ៉ែម សឿនជាស៊ីម*** *និងដួងវិញ្ញាណក្ខន្ធថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភាទាំងអស់ដែលបានចែកឋានទៅកាន់លោកខាងមុខ នៅវត្តមុនីប្រសិទ្ធីវង្ស(ហៅវត្តព្រែកព្នៅ) ស្ថិតនៅសង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ*

*-អញ្ជើញចូលរួមក្នុងពិធីកាន់បិណ្ឌវេនទី១២ នៅវត្តអង្គកំពង់ថ្មកែវ សង្កាត់ប្រទះឡាង ខណ្ឌកំបូល រាជធានីភ្នំពេញ*

*-អញ្ជើញចូលរួមក្នុងពិធីកាន់បិណ្ឌវេនទី១៣ នៅវត្តសំពោងផលអណ្តែត សង្កាត់និរោធន៍ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ*

-អញ្ជើញជាអធិបតីក្នុងពិធីបញ្ចុះសពឯកឧត្តមនាយឧត្តមសេនីយ៍ **ប៊ូ ថង** ឧត្តមក្រុមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាទីប្រឹក្សាសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា អតីតរដ្ឋមន្ត្រីក្រសួងការពារជាតិ អតីតអ្នកតំណាងរាស្ត្រ និងអតីតប្រធានគណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងព្រឹទ្ធសភា រដ្ឋសភា និងអធិការកិច្ចនៃព្រឹទ្ធសភា នៅវត្តភ្នំស្វាយ ក្រុងបានលុង ខេត្តរតនគិរី

-អញ្ជើញប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសល ជូនដល់ដួងវិញ្ញាណក្ខន្ធបុព្វការីជន និងញាតិកាទាំង៧សណ្តានរបស់សម្តេច និងលោកជំទាវ នៅភូមិភ្នំពេញថ្មី សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ និងនៅភូមិកំណើតរបស់សម្តេច នាឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម

-អញ្ជើញចូលរួមបុណ្យសព និងសំណេះសំណាលរំលែកទុក្ខក្រុមគ្រួសារនៃសពឯកឧត្តមឧត្តមសេនីយ៍ឯក **ស៊ឹម តៃ** នៅផ្ទះលេខ១១៥A ផ្លូវលេខ២០៧ រាជធានីភ្នំពេញ

-អញ្ជើញដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម **នួន សាមិន** ទីប្រឹក្សាសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងជាអតីតសមាជិកគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារីនៃព្រឹទ្ធសភា(នីតិកាលទី៣) នៅភូមិព្រៃទទឹង ស្រុកព្រៃឈរ ខេត្តកំពង់ចាម

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើព្រះរាជក្រឹត្យចំនួន១៥៤ច្បាប់ ទទួលព្រះរាជសារព្រះរាជទានសិទ្ធិចំនួន៧៨ច្បាប់ ទទួលសំណើពីរាជរដ្ឋាភិបាលចំនួន៧៧ច្បាប់ ពីប្រធានស្តីទីព្រឹទ្ធសភា ចំនួន០១ច្បាប់ និងជូនជ្រាបជាព័ត៌មានចំនួន៤២ច្បាប់។

**១.២-ឯកឧត្តម ស៊ុំ កា អនុប្រធានទី១ ព្រឹទ្ធសភា បាន :**

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញជាអធិបតីក្នុងអង្គវេទិកាភូមិភាគទី១ ក្រោមប្រធានបទស្តីពី: ការអនុវត្តថវិកាថ្នាក់ក្រោមជាតិ(រាជធានី ខណ្ឌ សង្កាត់) ក្នុងការអភិវឌ្ឍមូលដ្ឋាន ដើម្បីផ្តល់សេវាជូនប្រជាពលរដ្ឋ ប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព និងចូលរួមពិធីសម្ពោធអណ្តូងទឹកស្អាតស្ថិតនៅក្នុងវិទ្យាល័យទៀន សង្កាត់ទៀន ខណ្ឌដង្កោ រាជធានីភ្នំពេញ

-អញ្ជើញចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី៨ នៅវត្តទេពនីមិត្ត(ហៅវត្តអញ្ចាញ) ស្ថិតនៅឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង

-អញ្ជើញចូលរួមក្នុងពិធីបុណ្យ និងជាអធិបតីក្នុងពិធីបូជាសពឯកឧត្តមឧត្តមសេនីយ៍ឯក **ស៊ឹម តៃ** នៅវត្តឬស្សីសាញ់ ស្ថិតក្នុងសង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ

-អញ្ជើញចូលរួមពិធីបុណ្យគម្រប់ខួប៧ថ្ងៃ និង១០០ថ្ងៃសពឯកឧត្តមឧត្តមសេនីយ៍ឯក **ស៊ឹម តៃ** នៅផ្ទះលេខ១១៥A ផ្លូវលេខ២០៧ រាជធានីភ្នំពេញ

-ពិនិត្យ ផ្ដល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១១ច្បាប់ និងជូនជ្រាបជាព័ត៌មានចំនួន២២ច្បាប់។

**១.៣-ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន** :

-អញ្ជើញជួបសំណេះសំណាល និងសួរសុខទុក្ខសមាជិក សមាជិកា ក្រុមប្រឹក្សាឃុំ សង្កាត់ ប្រធានប៉ុស្តិ៍រដ្ឋបាល និងស្មៀនឃុំ សង្កាត់ ក្នុងស្រុកកណ្ដាលស្ទឹង ស្រុកអង្គស្នួល ស្រុកមុខកំពូល និងស្រុកពញាឮ ខេត្តកណ្ដាល សរុបចំនួន៣៧៦នាក់

-អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តមកពីប្រទេសបារាំងទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្ដាល

-អញ្ជើញនាំយកគ្រឿងឧបភោគបរិភោគ ទេយ្យទាន ទេយ្យវត្ថុ ទៅចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី១១ ចំនួន៤វត្ត មានដូចជា៖ វត្តប្រាំបីមុំ វត្តស្វាយអណ្ដែត វត្តទេពប្រណម្យ និងវត្តចម្លៀងផ្អែម ដើម្បីឧទ្ទិសកុសលទូវផល្លាអានិសង្សជូនបុព្វការីជនមានមាតា បិតា ជីដូន ជីតា ព្រមទាំងញាតិកាទាំង៧សណ្ដានដែលបានចែកឋាន នៅក្នុងឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ

-អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធ និងដឹកនាំប្រជុំគណៈកម្មការរៀបចំពិធីបុណ្យ និងបញ្ចុះសពឯកឧត្តមនាយឧត្តមសេនីយ៍ **ប៊ូ ថង** ឧត្តមក្រុមប្រឹក្សាផ្ទាល់**ព្រះមហាក្សត្រ** និងជាទីប្រឹក្សាសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា អតីតរដ្ឋមន្ត្រីក្រសួងការពារជាតិ អតីតអ្នកតំណាងរាស្ត្រ និងអតីតប្រធានគណៈកម្មការមហាផ្ទៃ ការពារជាតិ ទំនាក់ទំនងព្រឹទ្ធសភា រដ្ឋសភា និងអធិការកិច្ចនៃព្រឹទ្ធសភា នៅវត្តភ្នំស្វាយ ក្រុងបានលុង ខេត្តរតនគិរី

-អញ្ជើញចូលរួមក្នុងពិធីបុណ្យសព និងពិធីបូជាសពឯកឧត្តមឧត្តមសេនីយ៍ឯក **ស៊ឹម តៃ** នាយការិយាល័យចារកិច្ចនៃក្រសួងការពារជាតិ ក្រោមអធិបតីភាពឯកឧត្តម **ស៊ឹម កា** ប្រធានស្តីទីព្រឹទ្ធសភា នៅវត្តឫស្សីសាញ់ ស្ថិតក្នុងសង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ

-ពិនិត្យ ផ្ដល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៤៦ច្បាប់ និងជូនជ្រាបជាព័ត៌មានចំនួន១៥ច្បាប់។

## ២-គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

ក្នុងខែកញ្ញានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារតាមតួនាទីភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនយ៉ាងសកម្ម ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម:

## ២.១-មុខងារតាមដានការអនុវត្តច្បាប់

-អញ្ជើញចុះសិក្សាឈ្វេងយល់អំពី ការវិវត្តរីកចម្រើន បញ្ហាប្រឈមរបស់ខេត្តពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការដោយផ្តោតលើបញ្ហាសុខភាពសាធារណៈ ការអនុវត្តច្បាប់អន្តោប្រវេសន៍ ការផ្សព្វផ្សាយព័ត៌មាន ការអនុវត្តសិទ្ធិមនុស្ស ការអនុវត្តច្បាប់ ការផ្តល់ថវិកាពីថ្នាក់ជាតិសម្រាប់ការប្រើប្រាស់នៅក្នុងពន្ធនាគារដើម្បីធានាក្នុងការអនុវត្តសិទ្ធិអ្នកជាប់ឃុំ ការអនុវត្តថវិកា ការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈនៅថ្នាក់ក្រោមជាតិ នៅខេត្តសៀមរាប ខេត្តព្រះវិហារ ខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ

-អញ្ជើញចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្រុក ក្រុង និងថ្នាក់ដឹកនាំ និងមន្ត្រីនៃសាលាខេត្ត ព្រមទាំងតុលាការ និងអយ្យការអមតុលាការខេត្ត ដើម្បីឈ្វេងយល់អំពីការអនុវត្តច្បាប់ និងបញ្ហាប្រឈមនានាក្នុងការអនុវត្តក្រមទាំង៤ និងការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ នៅខេត្តតាកែវ ខេត្តកែប និងខេត្តកំពត

-អញ្ជើញចុះតាមដានការអនុវត្តច្បាប់ស្តីពីផ្លូវថ្នល់ និងបញ្ហាប្រឈមព្រមទាំងការឈ្វេងយល់អំពីដំណើរការចែកចាយ និងទូទាត់ថ្លៃថាមពលអគ្គិសនីនៅតាមអនុស្តានីយ៍នានា នៅខេត្តពោធិ៍សាត់

-អញ្ជើញចុះជួបសំណេះសំណាល និងពិភាក្សាការងារជាមួយថ្នាក់ដឹកនាំខេត្ត ប្រធានមន្ទីរ និងអង្គភាពពាក់ព័ន្ធ ដើម្បីឈ្វេងយល់អំពីការអនុវត្តច្បាប់ស្តីពី ការប្រឆាំងអំពើពុករលួយ ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងការអភិវឌ្ឍមូលដ្ឋាន នៅខេត្តព្រះវិហារ។

## ២.២-មុខងារតំណាង

-បានទទួលពាក្យបណ្តឹងចំនួន០១ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន ០១ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយចំនួន០៥ ករណី និងឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០៤ករណី កំពុងពិនិត្យសិក្សាចំនួន០២ករណី ព្រមទាំងទទួលឯកសារពាក្យបណ្តឹងដែលក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនគណៈកម្មការ ដើម្បីជូនជ្រាបចំនួន០៧ករណី

-អញ្ជើញចូលរួមវេទិកាភូមិភាគទី១ ក្រោមប្រធានបទស្តីពី ការអនុវត្តថវិកាថ្នាក់ក្រោមជាតិ (រាជធានី ខណ្ឌ សង្កាត់) ក្នុងការអភិវឌ្ឍមូលដ្ឋាន ដើម្បីផ្តល់សេវាជូន

ប្រជាពលរដ្ឋ ប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព និងចូលរួមពិធីសម្ពោធអណ្តូងទឹកស្អាតស្ថិតនៅក្នុងវិទ្យាល័យទៀន សង្កាត់ទៀន ខណ្ឌដង្កោ រាជធានីភ្នំពេញ

-អញ្ជើញចូលរួមសិក្ខាសាលាស្តីពី តួនាទីសភា ដើម្បីសម្រេចបានគោលដៅក្នុងការការពារ និងគ្រប់គ្រងជំងឺមិនឆ្លងក្នុងក្របខណ្ឌ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

-អញ្ជើញចូលរួមសិក្ខាសាលាស្តីពី នីតិវិធី និងបច្ចេកទេសនៃការតាក់តែងសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់

-អញ្ជើញចូលរួមសិក្ខាសាលាឈ្វេងយល់លើសេចក្តីព្រាងច្បាប់ស្តីពី សំណង់

-អញ្ជើញជាអធិបតីក្នុងពិធីប្រកាសសេចក្តីសម្រេចកែសម្រួលសមាសភាពគណៈកម្មការសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ នៅក្រុងសៀមរាប ខេត្តសៀមរាប

-អញ្ជើញចូលរួមកិច្ចប្រជុំលើកទី៤ ក្រោមប្រធានបទ តួនាទី ភារកិច្ចក្នុងការតាមដានរបស់គណៈកម្មការ គណៈកម្មាធិការការពារជាតិ និងសន្តិសុខនៃរដ្ឋសភាប្រទេសទាំងបីក្នុងការកសាងសហប្រតិបត្តិការ និងអភិវឌ្ឍន៍ព្រំដែនប្រកបដោយសន្តិភាព និងមិត្តភាព

សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះទៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងចំនួន១១១លើក ដើម្បីជួបពិភាក្សាការងារជាមួយអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋក្នុងការរកវិធានការជួយសង្គ្រោះប្រជាពលរដ្ឋដែលរងគ្រោះដោយទឹកជំនន់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព សិក្សាឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៨១លើក ។

**៣- កិច្ចសហប្រតិបត្តិការអន្តរជាតិ**

-ឯកឧត្តម **ម៉ាន់ ឈឿន** អញ្ជើញចូលរួមសិក្ខាសាលាស្តីពី លំនៅដ្ឋាននៅតំបន់អាស៊ី-ប៉ាស៊ីហ្វិច នៅទីក្រុងបាងកក នៃព្រះរាជាណាចក្រថៃឡង់ដ៍

-លោកជំទាវ **មាន សំអាន** ឯកឧត្តម **អាយ ខន** និងឯកឧត្តម **ឈិត គីមយាត** អញ្ជើញចូលរួមមហាសន្និបាតអាយប៉ា(AIPA) លើកទី៤០ នៅទីក្រុងបាងកក នៃព្រះរាជាណាចក្រថៃឡង់ដ៍

-លោកជំទាវ **ទី បូរ៉ាស៊ី** អនុញ្ញាតឱ្យលោកស្រី **Qin Deli** នាយកគ្រប់គ្រងកម្មវិធីទូទៅ Cambodia Digital TV Co.,LTD ខេត្តយូណាន នៃសាធារណរដ្ឋប្រជាមានិតចិន ជួបសម្ដែងការគួរសម និងពិភាក្សាការងារ

-ឯកឧត្ដមបណ្ឌិត **ម៉ុង ឫទ្ធី** អញ្ជើញជួបភ្ញៀវជប៉ុនដែលដឹកនាំដោយលោក **Motomobu Yoshimi** មកពីក្រុមហ៊ុន Sumitomo Corporation Asia &Oceania Pre Ltd ដែលចង់ប្រកួតប្រជែងដេញថ្លៃផ្គត់ផ្គង់ជីដាក់លើដំណាំដូងប្រេងសម្រាប់ឆ្នាំ២០១៩ ចំនួន៨.០០០តោន

-ឯកឧត្ដម **ម៉ាន់ ឈឿន** អញ្ជើញជួបពិភាក្សាការងារជាមួយលោកស្រី **Christiane Blancot** ក្រុមការងាររៀបចំ Congres de AIME (Association International des Maries Francophone) នៅរាជធានីភ្នំពេញ។

ថ្ងៃសុក្រ ១៣កើតខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩

**ជ.ប្រធានព្រឹទ្ធសភា**
**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ